**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ : ០១៨/២១ ក.ប/ស.ជ.លា.ខ.វ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ ជូនកម្មករនិយោជិតតាមរោងចក្រនៅរាជធានីភ្នំពេញ

អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ជូនកម្មករនិយោជិត នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដំណឹងដល់បងប្អូនកម្មករនិយោជិត ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ ទាំងអស់ ឱ្យបានជ្រាបថា តាមការកំណត់មុនពេលផ្តើមយុទ្ធនាការចាក់វ៉ាក់សាំងជូនបងប្អូនកម្មករនិយោជិត គឺអនុគណៈកម្មការចំពោះកិច្ចបានកំណត់គម្លាតនៃការចាក់ដូសទី១ និងដូសទី២ គឺមានរយៈពេល ៣សប្តាហ៍។ ហេតុដូច្នេះ ក្រុមគ្រូពេទ្យចាក់វ៉ាក់សាំងនឹងវិលត្រឡប់ទៅកាន់ទីតាំងរោងចក្រ ដែលធ្លាប់ចាក់ដូសទី១វិញ ចាប់ពីថ្ងៃទី២៨ ខែមេសា នេះតទៅ ដោយមានកាលវិភាគលម្អិត ដូចក្នុងឧបសម្ព័ន្ធនៃសេចក្តីជូនដំណឹងនេះ។

ចំពោះបងប្អូនកម្មករនិយោជិត ដែលរស់នៅក្បែរទីតាំងរោងចក្រ ឬរស់នៅក្នុងភូមិសាស្ត្រខណ្ឌតែមួយនៃរោងចក្រ ដែលខ្លួនបានទៅចាក់ដូសទី១ គឺត្រូវរង់ចាំការចាក់ដូសទី២ នៅតាមទីតាំងរោងចក្រ ដែលបានចាក់ដូសទី១កន្លងមក។

ចំពោះបងប្អូនកម្មករនិយោជិត ដែលរស់នៅក្នុងខណ្ឌផ្សេងនៃរាជធានីភ្នំពេញ ឬស្រុកនានានៃខេត្តកណ្តាលខុសពីទីតាំងរោងចក្រដែលជាកន្លែងចាក់ដូសទី១ ឬបងប្អូនដែលជាប់ការហាមឃាត់ធ្វើដំណើរ ហើយកំពុងស្នាក់នៅតាមបណ្តាខេត្តនានា សូមទំនាក់ទំនងមកអនុគណៈកម្មការចំពោះកិច្ចតាមរយៈកម្មវិធីតេឡេក្រាម https://t.me/workervaccination ដើម្បីអនុគណៈកម្មការចំពោះកិច្ចពិនិត្យសម្របសម្រួលកំណត់ទីតាំងថ្មីចាក់ជូន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនកម្មករនិយោជិត ដែលបានចាក់វ៉ាក់សាំងដូសទី១ នៅតាមរោងចក្រនានា រង់ចាំការចាក់វ៉ាក់សាំងដូសទី២ នៅតាមទីតាំងរោងចក្រដដែល ឬនៅទីតាំងថ្មីណាមួយ ដែលសម្របសម្រួលដោយអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងរបស់ក្រសួង ដើម្បីអាចរក្សាគម្លាតសង្គម និងចៀសវាងការទៅប្រមូលផ្តុំនៅទីតាំងណាមួយច្រើនពេក ដែលអាចបង្ករឱ្យមានការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ជាយថាហេតុ។

អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានជំនឿយ៉ាងមុតមាំថា បងប្អូនកម្មករនិយោជិត ម្ចាស់រោងចក្រ និងអ្នកពាក់ព័ន្ធទាំងអស់នឹងរួមគ្នាអនុវត្តទៅតាមស្មារតីនៃសេចក្តីជូនដំណឹងនេះ។

*ថ្ងៃសុក្រ ១២កើត ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤*
*រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១*

**ជ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ និងជាប្រធានអនុគណៈកម្មការចំពោះកិច្ច**
**ចាក់វ៉ាក់សាំងកូវីដ-១៩ ជូនកម្មករនិយោជិត**

**ហេង ស្វរ**

ឧបសម្ព័ន្ធ

# ទីតាំង និងកាលបរិច្ឆេទចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ ជូនកម្មករនិយោជិតតាមរោងចក្រ

| ល.រ | ខណ្ឌ | ទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ | កាលបរិច្ឆេទចាក់ដូសទី២ |
|---|---|---|---|
| ១ | ទួលគោក | ទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ចាប់ពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ |
| ២ | ពោធិសែនជ័យ | សួនឧស្សាហកម្មកាណាឌីយ៉ា | ថ្ងៃទី២៨ មេសា-ថ្ងៃទី២ ឧសភា ២០២១ |
| | | រោងចក្រ អាយ អេស អាយ (ISI) | ថ្ងៃទី២៨ មេសា-ថ្ងៃទី៥ ឧសភា ២០២១ |
| | | រោងចក្រ ស៊ីនចូវ | ថ្ងៃទី ២៩-៣០ មេសា ២០២១ |
| | | រោងចក្រ អប្សរា ហ្កាមែន | ថ្ងៃទី ៣ ឧសភា ២០២១ |
| | | រោងចក្រ រីលែអឺបិល ស៊ស (Reliable Source) | ថ្ងៃទី ៣-៥ ឧសភា ២០២១ |
| | | រោងចក្រ អាយ អាប់ប៉ារ៉ែល (I Apparel) | ថ្ងៃទី ៥-៦ ឧសភា ២០២១ |
| | | រោងចក្រ វ៉ាស់ អាប់ប៉ារ៉ែល (Vast Apparel) | ថ្ងៃទី ៣ ឧសភា ២០២១ |
| | | រោងចក្រ ធាន ស៊ុង (Tien Sung) | ថ្ងៃទី ៥ ឧសភា ២០២១ |
| ៣ | កំបូល | តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ | ថ្ងៃទី២៨ មេសា-ថ្ងៃទី៤ ឧសភា ២០២១ |
| | | រោងចក្រ ម៉ារ៉ែល | ថ្ងៃទី៣០ មេសា-ថ្ងៃទី៣ ឧសភា ២០២១ |
| | | រោងចក្រ មីនីបៀ | ថ្ងៃទី២៩ មេសា-ថ្ងៃទី៣ ឧសភា ២០២១ |
| | | រោងចក្រ នីយ៉ាន់ ឃីដ | ថ្ងៃទី២៩ មេសា-ថ្ងៃទី៣ ឧសភា ២០២១ |
| | | រោងចក្រ ស៊ីធី ស្ប៉ាក (City Spark) | ថ្ងៃទី ២-៣ ឧសភា ២០២១ |
| ៤ | ឫស្សីកែវ | រោងចក្រ មីជាតិ | ថ្ងៃទី៣០ មេសា-ថ្ងៃទី២ ឧសភា ២០២១ |
| | | រោងចក្រ ស្លែនឌីដ឵ ឆាន (Splendid Chance) | ថ្ងៃទី ៥-៦ ឧសភា ២០២១ |
| | | រោងចក្រ ស្ព័រតិច (Sportex) | ថ្ងៃទី ២-៣ ឧសភា ២០២១ |
| | | រោងចក្រ ហាយ ស៊ីនីជី (Hi-Synergy) | ថ្ងៃទី ១ ឧសភា ២០២១ |
| ៥ | ដង្កោ | សួនឧស្សាហកម្មវត្តខ្សាន:២ | ថ្ងៃទី៣០ មេសា-ថ្ងៃទី៥ ឧសភា ២០២១ |
| | | រោងចក្រ វ៉ាយ&ដាប់ប៊ែលយូ (Y&W) | ថ្ងៃទី ២៨-៣០ មេសា ២០២១ |
| | | រោងចក្រ អេវើ ស៊ូប្រា (Ever Subra) | ថ្ងៃទី ៣ ឧសភា ២០២១ |
| ៦ | សែនសុខ | រោងចក្រ ហ្គ្រីន វេ (Green Way) | ថ្ងៃទី ៣០ មេសា ២០២១ |